# សាធារណរដ្ឋប្រជាមានិតកម្ពុជា

**រដ្ឋសភា**

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

# ច្បាប់

## ស្តីពី

## ការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ

**មាត្រា ១** -ធនទណ្ឌគឺជាប្រាក់ពិន័យ ប្រាក់សំណងឬ ប្រាក់ជម្ងឺចិត្ត ។ របៀបទារធនទណ្ឌ គឺអាចទារប្រាក់ទាំង ៣មុខរួមគ្នាឬទារមួយមុខៗតាមគ្រប់វិធីដែលច្បាប់អនុញ្ញាតិនិងតាមផ្លូវដាក់គុកបង្ខំដល់រូបកាយផងក៏បាន ។

ធនទណ្ឌនេះ ត្រូវទារតាមអំណាចនៃសម្រង់សាលក្រមរបស់តុលាការដែលមានលក្ខណៈជាស្ថាពរហើយ ។ ប្រាក់សំណង និង ប្រាក់ជម្ងឺចិត្ត ត្រូវទារតាមបណ្តឹងរបស់ភាគីដើមបណ្តឹងដែលតុលាការបានសម្រេចសេចក្តី។ ប្រាក់ពិន័យ ប្រាក់សំណង ឬប្រាក់ជម្ងឺចិត្ត ដែលត្រូវបានទៅរដ្ឋ ត្រូវទារតាមបណ្តឹងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ២** -ការទារប្រាក់ពិន័យផង ប្រាក់សំណងផង ប្រាក់ជម្ងឺចិត្តផង ពីទណ្ឌិតដែលមានធនធានមិនគ្រប់គ្រាន់ គេត្រូវទារប្រាក់សំណង ប្រាក់ជម្ងឺចិត្តខ្លួនប្រាក់ពិន័យ ។ របៀបនៃការទារប្រាក់ពិន័យ ប្រាក់សំណង និង ប្រាក់ជម្ងឺចិត្ត ត្រូវអនុវត្តដូចគ្នា នឹងរបៀបនៃការទារប្រាក់សំណងក្នុងរឿងរដ្ឋប្បវេណីដែរ លើកលែងតែវិធីដាក់គុកបង្ខំ ដល់រូបកាយ ។

**មាត្រា ៣** -ការដាក់គុកបង្ខំដល់រូបកាយគឺជាវិធានការបង្ខំទណ្ឌិតអោយសងធនទណ្ឌតែប៉ុណ្ណោះ មិនមែនជាការកាត់កងអោយរួចពីធនទណ្ឌនោះទេ ។

នៅពេលដែលទណ្ឌិតបានរួចផុតពីកំណត់កាលដាក់គុកបង្ខំដល់រូបកាយ ប្រាក់ដែលទណ្ឌិតមិនទាន់បានសងប៉ុន្មាន ត្រូវនៅជំពាក់ទាំងអស់ដដែល ។ ប៉ុន្តែមិនត្រូវយកទណ្ឌិត នេះទៅដាក់គុកបង្ខំដល់រូបកាយជាថ្មីដើម្បីទារប្រាក់ជំពាក់ដែលនេះទៀតទេ ។

**មាត្រា ៤** -ជនដែលច្បាប់រដ្ឋប្បវេណីអោយរួចផុតពីការដាក់គុកបង្ខំដល់រូបកាយនោះ មិនត្រូវបានរួចផុតពីការដាក់គុកបង្ខំដល់រូបកាយ ក្នុងរឿងព្រហ្មទណ្ឌឡើយ ទោះបីជាប្រាក់ដែលជំពាក់នោះជាប្រាក់ពិន័យក្តី ប្រាក់សំណងក្តី ឬ ប្រាក់ជម្ងឺចិត្តក្តី។

នីតិជនអាយុតិចជាង ១៨ ឆ្នាំ និងមនុស្សវិកលចារិក មិនត្រូវដាក់គុកបង្ខំដល់រូបកាយ ដើម្បីទាមទារធនទណ្ឌនោះទេ ។

នឹងជនមានអាយុចាប់ពី ១៨ឆ្នាំ ឡើងមានសតិជានាល្អមានវិចារណញ្ញាណ ស្គាល់ខុសស្គាល់ត្រូវ ទើបដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារធនទណ្ឌនោះ ។

**មាត្រា ៥** -ក្នុងរឿងព្រហ្មទណ្ឌការសុំអោយដាក់គុកបង្ខំដល់រូបកាយនេះ ឥតមានបង់ថ្លៃអ្វីទេគឺថា បើមានភាគីដើមបណ្តឹង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ប្តឹងមកប្រធានតុលាការខេត្ត ក្រុង ខាងលំនៅរបស់ទណ្ឌិត ត្រូវចេញដីកា បង្គាប់បញ្ជាអោយយកទណ្ឌិតទៅដាក់គុកបង្ខំដល់រូបកាយ ដោយគ្មានអោយចេញ ឬ អោយតម្កល់ប្រាក់ថ្លៃអាហារទេ ថ្វីបើមានប្រើសិទ្ធរឹបអូសលក់តាមផ្លូវច្បាប់នូវចលនវត្ថុ អចលនវត្ថុក៏ដោយ ប្រធានតុលាការចេញដីកានេះ ដោយសំអាងទៅលើសម្រង់ក្រមដែលមានសេចក្តីសម្រេចជាស្ថាពរ ។

ប៉ុន្តែនៅពេលកំពុងអនុវត្តការដាក់គុកបង្ខំដល់រូបកាយនោះ ទណ្ឌិតបានសងធនទណ្ឌគ្រប់ចំនួនហើយ ប្រធានតុលាការត្រូវចេញដីកា បង្គាប់បញ្ជាដោះលែងទណ្ឌិតនោះ ចេញពីពន្ធនាគារភ្លាម ។

**មាត្រា ៦** -រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចអនុញ្ញាតិអោយបង្អង់អនុវត្ត នូវការដាក់គុកបង្ខំដល់រូបកាយបាន កាលបើទណ្ឌិតនោះមានសុខភាពល្អ គួរអោយបង្អង់ហើយទណ្ឌិតក៏ឥតមានជាប់គុកពីបទល្មើសណាទៀតទេ ក្នុងពេលដែលអោយបង្អង់នេះ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នឹងអនុញ្ញាតិអោយបានក៏លុះណាតែមានភស្តុតាងច្បាស់លាស់គឺសេចក្តីសន្និដ្ឋានរបស់ពេទ្យ ដែលពិនិត្យអាការរោគទណ្ឌិតនោះផងដែរ ។ សាម៉ីជនអ្នកសុំអោយពេទ្យពិនិត្យនោះត្រូវបង់ប្រាក់ថ្លៃពិនិត្យនេះនៅការិយាល័យ ក្រឡាបញ្ជីនៃសាលាជម្រះក្តីខាងលំនៅរបស់ខ្លួន ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចអនុញ្ញាតិអោយបង្អង់យ៉ាងនេះ បានតែក្នុងរយៈវេលា មួយខែគត់ ប៉ុន្តែបើទណ្ឌិតបានសំបុត្រពេទ្យជាថ្មីទៀត ទណ្ឌិតអាចសុំអោយបង្អង់ម្តងមួយបានជាដរាប ការសុំបន្តម្តងៗ ទណ្ឌិតត្រូវមានសេចក្តីសន្និដ្ឋានរបស់ពេទ្យជាថ្មីទៀតគ្រប់តែដងដាច់ខាត។

**មាត្រា ៧** -របៀបដាក់គុកបង្ខំដល់រូបកាយ ត្រូវដាក់គុកមួយថ្ងៃក្នុងប្រាក់ជំពាក់ប្រាំរយរៀល ៥០រៀល ឬ តិចជាងប្រាំរយរៀល ៥០០រៀល ។

បើប្រាក់ជំពាក់នោះមានចំនួនច្រើនដល់ដប់ម៉ឺនរៀល ១០០.០០០រៀល ការដាក់គុកនេះត្រូវគិតក្នុងមួយថ្ងៃប្រាំរយរៀល៥០០រៀល ដរាបអស់ប្រាក់ដប់ម៉ឺនរៀល ១០០.០០០រៀល បើប្រាក់ជំពាក់នោះលើសពីដប់ម៉ឺនរៀល ១០០.០០០រៀល ទៅការនេះត្រូវគិតពីត្រឹមប្រាក់លើសនោះមួយពាន់រៀល១.០០០រៀល ក្នុងមួយថ្ងៃ ប៉ុន្តែទោះបីប្រាក់ជំពាក់នោះមានចំនួនច្រើនយ៉ាងណាក៏ដោយ ក៏រយៈវេលាដែលត្រូវដាក់គុកទណ្ឌិតតែម្នាក់ឯងក្នុងរឿងតែមួយ ដោយសរុបទាំងអស់មិនត្រូវអោយលើពី ពីរឆ្នាំទេ ។

**មាត្រា ៨** -បើទណ្ឌិតតែម្នាក់ ឬ ច្រើននាក់ជំពាក់ធនទណ្ឌ ព្រោះខ្លួនបានប្រព្រឹត្តបទល្មើសមួយបទ ឬច្រើនបទដែលត្រូវរួមគ្នាសងភាគីដើមបណ្តឹងតែម្នាក់ រយៈវេលានៃការដាក់គុកបង្ខំដល់រូបកាយ នោះត្រូវគិតតួររបៀបខាងលើគ្រប់រូបទណ្ឌិតទាំងអស់ គឺ បើគិតទៅឃើញ ២០ថ្ងៃ ត្រូវដាក់២០ថ្ងៃ ទាំងអស់គ្នា។

បើទណ្ឌិតតែម្នាក់ ឬ ច្រើននាក់ជានារីនៃបទល្មើសមួយបទ ឬ ច្រើនបទ ដែលត្រូវរួបរួមគ្នាបង់ធនទណ្ឌតអោយភាគីដើមបណ្តឹងច្រើននាក់រយៈវេលាដាក់គុកបង្ខំដល់រូបកាយត្រូវបំបែក តាមចំនួនប្រាក់របស់ភាគីដើមម្នាក់ៗ អោយដាច់ពីគ្នា មិនត្រូវបូករួមសំណងជម្ងឺចិត្តរបស់ភាគីទាំងអស់ចូលគ្នាជាចំនួនមួយនោះទេ ។

ក្នុងការដែលមានធនទណ្ឌខាងពិន័យផង ខាងជម្ងឺចិត្តផង ត្រួតគ្នាយ៉ាងនេះរយៈវេលាដាក់គុកត្រូវញែកប្រាក់ពិន័យ និងប្រាក់ជម្ងឺចិត្តអោយដាច់ពីគ្នា ហើយគិតថ្ងៃដាក់គុកតាមពិន័យដោយខ្លួន តាមជម្ងឺចិត្តដោយខ្លួន កុំបូកប្រាក់ពិន័យ និង ប្រាក់ជម្ងឺចូលចិត្តគ្នាឡើយ ។

**មាត្រា ៩** -កាលបើទណ្ឌិតច្រើននាក់ ខ្លះជាចារី ខ្លះជាសហចារី ខ្លះជាអ្នកសមគំនិតហើយត្រូវទណ្ឌកម្មអោយរួបរួមគ្នាសងជម្ងឺចិត្តនោះរយៈវេលាដាក់គុកបង្ខំដល់រូបកាយត្រូវគិតទៅលើទណ្ឌិតម្នាក់ៗ នូវចំនួនថ្ងៃដាក់គុក ដូចជាទណ្ឌិតនោះត្រូវទោសតែម្នាក់ឯង គឺថាមិនត្រូវយកចំនួនប្រាក់នោះមករំលែកជាភាគចែកគ្នាដាក់គុកតាមចំណែកសព្វខ្លួននោះបានទេ ។

រយៈវេលាដែលត្រូវដាក់គុកបង្ខំទារប្រាក់នេះទៀត ក៏មិនត្រូវបន្ថយបន្ថែមអ្វីអោយខុសពីរបៀបគិត ដូចបានពោលមកនោះទេ ។

ឯប្រាក់ពិន័យ ដែលតុលាការដាក់ទណ្ឌកម្មអោយម្នាក់ៗបង់នោះមិនត្រូវយកចំនួនប្រាក់ពិន័យនោះមកសរុបគ្នាបង់ទេ គឺត្រូវបង់តាមចំណែកសព្វខ្លួន ការដាក់គុកបង្ខំទារប្រាក់នោះទៀត ក៏ត្រូវដាក់គុកតាមចំណែកប្រាក់ពិន័យសព្វខ្លួនដែរ ។

**មាត្រា ១០** -ជាគោលការណ៍ក្នុងរឿងព្រហ្មទណ្ឌដូចជាគ្នារឿងរដ្ឋប្បវេណី ការទារធនទណ្ឌអាចនឹងធ្វើទៅបានលុះណាតែមានរូបមន្តបង្គាប់ដែលបានកំណត់នៅក្នុងសាលក្រម ។

ក្នុងរឿងព្រហ្មទណ្ឌមិនចាំបាច់អោយមានបណ្តឹងពីភាគីដើមបណ្តឹង តុលាការត្រូវតែសម្រេចបង្គាប់អោយដាក់គុកបង្ខំដល់រូបកាយដើម្បីទារធនទណ្ឌ បើកូនបំណុលមិនព្រមសង ។

ក្នុងរឿងរដ្ឋប្បវេណី នៅពេលមុនសម្រេចសេចក្តីចាំបាច់ត្រូវតែមានបណ្តឹងពីភាគី ដើមបណ្តឹងទើបតុលាការ អោយសម្រេច ដាក់គុកបង្ខំដល់រូបកាយ ដើម្បីទារប្រាក់ជំពាក់កាលបើកូនបំណុលមិនព្រមសង ក្នុងបទនេះតុលាការមិនត្រូវបង្ខំ ឬ ណែនាំដល់កូនក្តីអោយប្តឹងសុំនោះទេ ។

**មាត្រា ១១** -ក្នុងសេចក្តីចម្លងសាលក្រម ឬ សម្រង់សាលក្រមដែលត្រូវយកទៅអនុវត្តត្រូវតែមានរូបមន្តបង្គប់ឱ្យអនុវត្តផងដាក់នៅខាងចុងសាលក្រម ឬ សម្រង់សាលក្រមនេះរូបមន្តបង្គប់នោះមានដូចតទៅៈ

ប្រមុខរដ្ឋ នៃរដ្ឋកម្ពុជាបង្គាប់មកអ្នកអនុវត្តសាលក្រមឱ្យសម្រេចតាមសាលក្រមនេះ និងឱ្យអាជ្ញាធរគ្រប់តំណែងគ្រប់ថ្នាក់ជួយអនុវត្តសាលក្រមនេះបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

**មាត្រា ១២** -ជាគោលការណ៍សម្រង់សាលក្រមព្រហ្មទណ្ឌ ក្រឡាបញ្ជីត្រូវចារសម្គាល់ពីអនុភាព នៃសាលក្រមហើយស្រង់ថ្ងៃដែលដាក់គុកបង្ខំដល់រូបរាងកាយ ដើម្បីទារធនទណ្ឌ និងស្រង់រូបមន្តដាក់នៅចុងសាលក្រមនោះផង ។ ក្នុងករណីមិនបានអនុវត្តតាមសាលក្រមនេះទេ ក្រឡាបញ្ជីដែលចេញសាលក្រមត្រូវទទួលទោសពិន័យជាប្រាក់ ប្រាំពាន់រៀល ៥០០០រៀល ។

រូបមន្តដែលត្រូវស្រង់ចូលមានចែងនៅក្នុងមាត្រា ១១ នៃច្បាប់នេះ ។

**មាត្រា ១៣** -កងកម្លាំងប្រដាប់អាវុធនគរបាលប្រជាជន អង្គការរដ្ឋអំណាចមូលដ្ឋាន គ្រប់ថ្នាក់ត្រូវជួយការងារអនុវត្តសាលក្រមអោយបានសម្រេច កាលបើមានសំណូមពរ ត្រឹមត្រូវតាមច្បាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជាអនុម័តនៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៩២ សម័យប្រជុំលើទី២២ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៩២

ជ-រដ្ឋសភា

ប្រធាន

ហត្ថលេខា និងត្រា

**ជា ស៊ីម**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

អគ្គលេខាធិការក្រុមប្រឹក្សារដ្ឋ